**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តកោះកុង**
**រដ្ឋបាលស្រុកគិរីសាគរ**
លេខៈ០៧៣/ស្រុ.ជ.ណ

ថ្ងៃអង្គារ ១១រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ស្រុកគិរីសាគរ ថ្ងៃទី...០៩.....ខែ..មីនា..ឆ្នាំ២០២១

**ជម្រាបជូន**
**លោកមេឃុំគ្រប់ឃុំ នៃរដ្ឋបាលស្រុកគិរីសាគរ**

**កម្មវត្ថុ** ៖ ស្តីពីការផ្អាកជាបណ្តោះអាសន្ន កម្មវិធីអាពាហ៍ពិពាហ៍ និងពិធីជប់លៀងផ្សេងៗ ។

**កម្មវត្ថុ** ៖ ស្មារតីកិច្ចប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្តកោះកុង កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោកមេឃុំគ្រប់ឃុំ** មេត្តាជ្រាបថា: ក្នុងស្ថានភាពបច្ចុប្បន្ននេះ ជំងឺកូវីដ១៩ បាននឹងកំពុងរីករាលដាលក្នុងសហគមន៍ ពាក់ព័ន្ធព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ដូចនេះ ដើម្បីចូលរួមបង្ការការពារ និងទប់ស្កាត់ការរីករាលដាលឆ្លងជំងឺកូវីដ១៩ សូម **លោកមេឃុំ** ផ្សព្វផ្សាយដល់បងប្អូនប្រជាពលរដ្ឋផ្អាកជាបណ្តោះអាសន្ន **កម្មវិធីអាពាហ៍ពិពាហ៍ និងពិធីជប់លៀងផ្សេងៗ** ចាប់ពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១តទៅ រង់ចាំការជូនដំណឹងជាថ្មី។ ជាមួយគ្នានេះ ត្រូវណែនាំបងប្អូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន សូមមានការប្រុងប្រយ័ត្នឱ្យបានខ្ពស់ និងត្រូវអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាល និងការណែនាំរបស់រាជរដ្ឋាភិបាល ជាពិសេសត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួន លើវិធានការណ៍ ៣ការពារ និង៣កុំ។

អាស្រ័យហេតុនេះ សូម **លោកមេឃុំគ្រប់ឃុំ** ចាត់ចែងអនុវត្តអោយមានប្រសិទ្ធិភាពខ្ពស់។

សូម **លោកមេឃុំ** ទទួលនូវការគោរពអំពីខ្ញុំ។

**អភិបាលស្តីទី**

**ទូត ហានីហ៍**

<u>ចម្លងជូន</u>
- រដ្ឋបាលខេត្តកោះកុង
- ក្រុមប្រឹក្សាស្រុកគិរីសាគរ
(ដើម្បីជូនជ្រាប)
- ឯកសារ -កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

---

**ខេត្តកោះកុង**
**រដ្ឋបាលស្រុកបូទុមសាគរ**
លេខ:...០២៤/២១ស.ជ.ណ

ថ្ងៃ[illegible]ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ស្រុកបូទុមសាគរ.ថ្ងៃទី...០៩...ខែមីនា ឆ្នាំ២០២១

**ជម្រាបជូន**
**លោកមេឃុំគ្រប់ឃុំ ចំណុះឱ្យរដ្ឋបាលស្រុកបូទុមសាគរ**

**កម្មវត្ថុ:** ស្តីពីការផ្អាកជាបណ្តោះអាសន្ន **កម្មវិធីអាពាហ៍ពិពាហ៍ និងពិធីជប់លៀងផ្សេងៗ ។**
**យោង:** ស្មារតីកិច្ចប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្តកោះកុង កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោកមេឃុំគ្រប់ឃុំ** មេត្តាជ្រាបថា: ក្នុងស្ថានភាពបច្ចុប្បន្ននេះ **ជំងឺកូវីដ-១៩** បាននឹងកំពុងរីករាលដាលក្នុងសហគមន៍ ពាក់ព័ន្ធព្រឹត្តិការណ៍ថ្ងៃ២០កុម្ភៈ។ ដើម្បីចូលរួមបង្ការ និងទប់ស្កាត់ការរីករាលដាលឆ្លង **ជំងឺកូវីដ-១៩** សូម **លោកមេឃុំគ្រប់ឃុំ** ផ្សព្វផ្សាយដល់បងប្អូនប្រជាពលរដ្ឋផ្អាកជាបណ្តោះអាសន្ន **កម្មវិធីអាពាហ៍ពិពាហ៍ និងពិធីជប់លៀងផ្សេងៗ** ចាប់ពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១តទៅ រង់ចាំការជូនដំណឹងជាថ្មី។ ជាមួយគ្នានេះ ត្រូវណែនាំបងប្អូនប្រជាពលរដ្ឋ ចូលរួមការពារ ការឆ្លងនៃ**ជំងឺកូវីដ-១៩** ដោយអនុវត្តអោយបានខ្ជាប់ខ្ជួន តាមវិធានការរបស់ក្រសួងសុខាភិបាល។

អាស្រ័យហេតុនេះ សូម **លោកមេឃុំគ្រប់ឃុំ** ចាត់ចែងអនុវត្ត អោយមានប្រសិទ្ធិភាពខ្ពស់។

សូម **លោកមេឃុំ** ទទួលនូវការគោរពរាប់អានដ៏ស្មោះអំពីខ្ញុំ។

**អភិបាលស្តីទី**

រិទ្ធ សោភ័ណ្ឌ

**__ចម្លងជូន__**
-រដ្ឋបាលខេត្តកោះកុង
-ក្រុមប្រឹក្សាស្រុកបូទុមសាគរ
*(ដើម្បីជូនជ្រាប)*
-ឯកសារ -កាលប្បវត្តិ